**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ...៧១៧៥...អពដ

L202104130109 | TD2799

ថ្ងៃសុក្រ ៥កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ ភ្នាក់ងារសេវាកម្មពន្ធដារ និងសាធារណជនទាំងអស់ជ្រាបថា យោងតាមសេចក្តីសម្រេចលេខ ៤៩ សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនអ្នកជាប់ពន្ធនិងភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ដែលនៅក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ធ្វើការបំពេញលិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែតាមអនឡាញ (Online) ដែលអគ្គនាយកដ្ឋានពន្ធដារបានអភិវឌ្ឍ និងបានដាក់ឱ្យប្រើប្រាស់នាពេលកន្លងមក។ ក្នុងន័យនេះ អ្នកជាប់ពន្ធទាំងអស់អាចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែតាមអនឡាញ ដោយអនុវត្តតាមជម្រើសមធ្យោបាយដូចខាងក្រោម÷

១. សម្រាប់អ្នកជាប់ពន្ធមធ្យមនិងធំអាចបំពេញនិងដាក់លិខិតប្រកាសប្រចាំខែតាមរយៈការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធប្រចាំខែ (E-Filing) និងធ្វើការទូទាត់ប្រាក់ពន្ធតាមរយៈការប្រើប្រាស់ប្រព័ន្ធទូទាត់ប្រាក់ពន្ធតាមអនឡាញ (E-Payment) ដោយចូលទៅកាន់អាសយដ្ឋាន https://www.tax.gov.kh/km/e-service ។ សម្រាប់អ្នកជាប់ពន្ធតូចអាចបំពេញនិងដាក់លិខិតប្រកាសប្រចាំខែតាមរយៈកម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) ដែលអាចចូលទៅទាញយកបានតាម App Store (សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទដៃតាមប្រព័ន្ធ iOS) ឬ Play Store (សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទដៃតាមប្រព័ន្ធ Android) និងអាចធ្វើការទូទាត់ប្រាក់ពន្ធជាស្វ័យប្រវត្តិ។ សម្រាប់នីតិវិធីលម្អិតសូមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំលេខ ០០៣ សហវ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានភ្ជាប់ជាឧបសម្ព័ន្ធស្រាប់។

២. ក្នុងករណីអ្នកជាប់ពន្ធនៅមិនទាន់មានលទ្ធភាពប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធប្រចាំខែ (E-Filing) ឬកម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) អ្នកជាប់ពន្ធអាចបំពេញលិខិតប្រកាសពន្ធប្រចាំខែដោយដៃ និងបង់ប្រាក់ពន្ធដោយប្រើប្រាស់ប្រព័ន្ធទូទាត់ប្រាក់ពន្ធតាមអនឡាញ (E-Payment) រួចស្កេនបញ្ជូនលិខិតប្រកាសនិងបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធតាមរយៈប្រព័ន្ធបញ្ជូនឯកសារអេឡិចត្រូនិក (E-Document) ដោយចូលទៅកាន់អាសយដ្ឋាន https://www.tax.gov.kh/km/e-service ។ សម្រាប់នីតិវិធីលម្អិតសូមអនុវត្តដូចខ្លឹមសារនៃសេចក្តីណែនាំលេខ ៧៧០៥ អពដ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានពន្ធដារ ដែលមានភ្ជាប់ជាឧបសម្ព័ន្ធស្រាប់។

ដើម្បីជាការសម្រួលដល់ដំណើរការនៃការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែ សម្រាប់អ្នកជាប់ពន្ធដែលស្ថិតនៅក្នុងប្រភេទអាជីវកម្មត្រូវបានអនុញ្ញាតឱ្យបន្តសកម្មភាពក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ ដូចមានចែងក្នុងប្រការ ៣ នៃសេចក្តីសម្រេចលេខ ៤៩ សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និង

L202104130109 | TD2799

ក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងអ្នកជាប់ពន្ធដែលមិនស្ថិតក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ កាលបរិច្ឆេទផុតកំណត់ឱ្យដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែមីនា ដែលត្រូវធ្វើនៅក្នុងខែមេសានេះ នឹងត្រូវបានអនុញ្ញាតឱ្យពន្យាររហូតដល់ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១។ ដោយឡែក អ្នកជាប់ពន្ធដែលស្ថិតក្នុងប្រភេទអាជីវកម្មដែលត្រូវបានហាមឃាត់ក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ កាលបរិច្ឆេទផុតកំណត់ឱ្យដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែមីនា ដែលត្រូវធ្វើនៅក្នុងខែមេសានេះ នឹងត្រូវបានអនុញ្ញាតឱ្យពន្យាររហូតដល់ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១។

បន្ថែមពីនេះ ក្នុងគោលដៅគាំទ្រដល់ការប្រើប្រាស់និងផ្តល់ភាពងាយស្រួលជូនអ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំរួចរាល់នូវក្រុមការងារសេវាគាំទ្រ (e-Tax Service) ដើម្បីដោះស្រាយបញ្ហានានាក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសតាមអនឡាញ និងមជ្ឈមណ្ឌលCall Center 1277 ដើម្បីដោះស្រាយឬឆ្លើយតបនឹងចម្ងល់និងបញ្ហានានារបស់អ្នកជាប់ពន្ធ។ ដោយឡែក ក្នុងរយៈពេលនៃការបិទខ្ទប់ អគ្គនាយកដ្ឋានពន្ធដារសូមជំរុញនិងលើកទឹកចិត្តឱ្យភ្នាក់ងារសេវាកម្មពន្ធដារដែលជួបប្រទះបញ្ហាប្រឈមក្នុងការទទួលនិងបញ្ជូនឯកសារពីអ្នកជាប់ពន្ធជាអតិថិជនដើម្បីរៀបចំប្រកាស និងបង់ប្រាក់ពន្ធប្រចាំខែគួរប្រើប្រាស់សារអេឡិចត្រូនិក (E-mail) ឬមធ្យោបាយអេឡិចត្រូនិកនានា ដើម្បីបញ្ជូននិងទទួលឯកសារជាទម្រង់ Soft Copy និងរៀបចំប្រកាសនិងបង់ប្រាក់ពន្ធតាមយន្តការខាងលើ។

សេចក្តីដូចបានជម្រាបខាងលើ សូមអ្នកជាប់ពន្ធ ភ្នាក់ងារសេវាកម្មពន្ធដារ និងសាធារណជនទាំងអស់ ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

**អគ្គនាយកដ្ឋានពន្ធដារ**